ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ២០៤៩ ឧ.ស

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិត្តិយសសូមគោរពទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជន ប្រើប្រាស់ទឹករបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញទូទាំងរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ មេត្តាជ្រាបថា ដោយអនុវត្តនយោបាយបញ្ចុះថ្លៃលក់ទឹករបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានចេញសេចក្តីសម្រេចស្តីពីការកែសម្រួលថ្លៃលក់ទឹកស្អាត ដែលផលិត និងផ្គត់ផ្គង់ដោយរដ្ឋាករទឹកស្វយ័តក្រុង ភ្នំពេញ លេខ ១៤៩ MIH/២០១៧ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៧ ដោយបានបន្ថែមកំរិតប្រើប្រាស់ ពី ០ ទៅ ៣ ម$^{៣}$ ថ្លៃត្រឹមតែ ៤០០ រៀល ក្នុងមួយម៉ែត្រគូបតែប៉ុណ្ណោះ ដែលពីមុនមានថ្លៃ ៥៥០ រៀល ក្នុងមួយម៉ែត្រគូប ។

អនុវត្តតាមសេចក្តីសម្រេចនេះ ដោយមានកំហុសបច្ចេកទេស រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានធ្វើការគណនា និងចេញវិក្កយបត្រពុំត្រឹមត្រូវបណ្តាលឲ្យមានការកើនតម្លៃទឹកប្រើប្រាស់របស់ប្រជាជន នៅរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ ។

ចំពោះការខុសឆ្គងនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមអភ័យទោស ពីសំណាក់អតិថិជនទាំងអស់ ដែលមានផលប៉ះពាល់ពីការខុសឆ្គងនេះ ហើយសន្យាថានឹងមិនឲ្យមានការខុសឆ្គងជាលើកទី ២ ឡើយ។ ទន្ទឹមនេះ ក្រសួងបានបញ្ជាឲ្យរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញអនុវត្តការគណនាតម្លៃទឹកតាមរបៀបគណនាចាស់ និងសងជូនអតិថិជនដែលមានផលប៉ះពាល់ ទាំងអស់ នូវទឹកប្រាក់លម្អៀងលើសជាបន្ទាន់ ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនប្រើប្រាស់ទឹករបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញទូទាំងរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ មេត្តាជ្រាប និងយោគយល់អធ្យាស្រ័យចំពោះការខុសឆ្គងអចេតនានេះ ។

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone : 855-23-211141, Fax: 855-23-428263